ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Sep-2012, 09:44
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១៦)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(16)

| | |
|---|---|
| នៅចំពោះមុខ: | **ចៅក្រម គង់ ស្រ៊ឹម ប្រធាន** |
| កាលបរិច្ឆេទ: | **ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២** |
| ភាសា: | **ខ្មែរ/អង់គ្លេស** |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

---

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្ដីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>ជនជាប់ចោទ</u>**

អៀង ធីរិទ្ធ

**<u>មេធាវីជនជាប់ចោទ</u>**

ផាត់ ពៅស៊ាង
Diana ELLIS, QC

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**កត់សម្គាល់** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ បង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ("ដីកាបង្គាប់ឲ្យដោះលែង")[1]

**ទទួលបាន** សំណើរបស់សហព្រះរាជអាជ្ញាដោយអនុលោមតាមវិធាន ៨២(៦) នៃវិធានផ្ទៃក្នុង (វិសោធនកម្ម លើកទី ៨) សុំផ្អាកសេចក្តីសម្រេចបង្គាប់ឲ្យដោះលែង ("សំណើសុំ")[2] ដោយភ្ជាប់ជាមួយនឹងឯកសារថតចម្លង នៃបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបង្គាប់ឱ្យដោះលែងដាក់ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ("បណ្តឹងសាទុក្ខ")[3] ដែលសហព្រះរាជអាជ្ញាស្នើសុំថា ជនជាប់ចោទត្រូវទទួលការត្រួតពិនិត្យតាមផ្លូវតុលាការ ជាពិសេសជាងនេះទៀតនោះការដោះលែងជនជាប់ចោទត្រូវភ្ជាប់នូវលក្ខខណ្ឌដូចតទៅ: i) ត្រូវស្ថិតនៅក្នុងលំនៅដ្ឋានដែលមានអាស័យដ្ឋានជាក់លាក់ដែលផ្តល់ដោយសហមេធាវីការពារក្តី, ii) ត្រូវបង្ហាញខ្លួនដើម្បីត្រួតពិនិត្យសុវត្ថិភាពពីរដ្ឋអំណាច ឬមន្ត្រីដែលបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង iii) ត្រូវប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ, iv) មិនត្រូវទាក់ទង ដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងជនជាប់ចោទដទៃទៀត (លើកលែងប្តីរបស់ខ្លួន អៀង សារី), v) មិនត្រូវទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយសាក្សី អ្នកជំនាញ ឬជនរងគ្រោះណាមួយ ដែលបានស្នើឡើងដើម្បីធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ, vi) ត្រូវទទួលការត្រួតពិនិត្យដោយអ្នកជំនាញវិជ្ជសាស្ត្រ ដែលចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូងរៀងរាល់ប្រាំមួយ(០៦)ខែម្តង[4]

---

[1] សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារលេខ E138/1/10។

[2] សំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារលេខ E138/1/10/2, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[3] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការបន្ទាប់ពីសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារលេខ E138/1/10/1។

[4] បណ្តឹងសាទុក្ខ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារលេខ E138/1/10/1, កថាខណ្ឌ ១០។

**ដោយពិចារណាឃើញថា** សហព្រះរាជអាជ្ញាមិនបានជំទាស់លើការដោះលែងជនជាប់ចោទទេ ប៉ុន្តែ គ្រាន់តែបានប្តឹងសាទុក្ខទៅលើការបង្គាប់ឱ្យដោះលែង ត្រង់ចំណុចស្តីពីលក្ខខណ្ឌនៃការដោះលែងនោះ

**ដោយពិចារណាឃើញថា** សិទ្ធិរបស់ជនជាប់ចោទទទួលបានសេរីភាព ដែលត្រូវបានការពារតាមច្បាប់កម្ពុជា[5] និងមាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចត្រូវបានកម្រិតតែក្នុងករណីចាំបាច់ និងតែក្នុងករណីដែលការដាក់វិធានការនេះមានលក្ខណៈសមស្របទៅនឹងគោលបំណងដែលចង់បានប៉ុណ្ណោះ

**ដោយពិចារណាឃើញថា** ការឃុំខ្លួនជនជាប់ចោទ មិនមានភាពចាំបាច់ ក្នុងអំឡុងពេលរង់ចាំការសម្រេចលើបណ្តឹងសាទុក្ខ ដែលកម្រិតត្រឹមតែលក្ខខណ្ឌនៃការដោះលែង ហើយមិនមែនជាវិធានការ ដែលមានលក្ខណៈសមស្របនៅក្នុងកាលៈទេសៈនេះទេ

**ដោយពិចារណាឃើញថា** រាល់លក្ខខណ្ឌដែលស្នើឡើងដោយសហព្រះរាជអាជ្ញា មានខ្លឹមសារមិនជំទាស់ទៅនឹងការដោះលែងឱ្យមានសេរីភាព ក្នុងអំឡុងពេលរង់ចាំការសម្រេចលើបណ្តឹងសាទុក្ខ

**ដោយពិចារណាឃើញថា** ទោះបីជាយ៉ាងណាក៏ដោយ ត្រូវតែមានវិធានការដើម្បីធានាថា ជនជាប់ចោទ ស្ថិតក្រោមការចាត់ចែងរបស់តុលាការ នៅក្នុងអំឡុងពេលរង់ចាំការសម្រេចលើបណ្តឹងសាទុក្ខដោយហេតុថា ឧក្រិដ្ឋកម្មដែលប្តឹងចោទប្រកាន់លើជនជាប់ចោទ មានភាពធ្ងន់ធ្ងរ ដូច្នេះគប្បីដាក់លក្ខខណ្ឌចំពោះការដោះលែងជនជាប់ចោទ ក្នុងអំឡុងពេលរង់ចាំការសម្រេចលើបណ្តឹងសាទុក្ខ

**ដោយពិចារណាឃើញថា** ប្រធានអង្គជំនុំជម្រះតុលាការកំពូល មានអំណាចក្នុងការបង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ ដោយយោងតាមវិធាន ៨២(៦) នៃវិធានផ្ទៃក្នុង ដូច្នេះ ជាការសមហេតុផល ប្រធាន ក៏មានអំណាចក្នុងការសម្រេចនូវវិធានការដែលពុំមានភាពរិតត្បិតដែរ[6]

**ដោយអនុលោមតាម** វិធាន ៨២(៦) នៃវិធានផ្ទៃក្នុង

---

[5] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា យោងលើសេចក្តីសម្រេចលើបណ្តឹសាទុក្ខប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, E138/1/7, កថាខណ្ឌ ៣៩។

[6] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, E138/1/7, កថាខណ្ឌ ៤៥។

**សម្រេច:**

**ទទួលយក** ផ្នែកខ្លះនៃសំណើរបស់សហព្រះរាជអាជ្ញា។

**បង្គាប់** ឱ្យដោះលែងជនជាប់ចោទ ប៉ុន្តែផ្អាកការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រង់ចំណុចដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ។

**បង្គាប់ថា** ក្នុងពេលរង់ចាំការសម្រេចលើបណ្តឹងសាទុក្ខនេះ ការដោះលែងជនជាប់ចោទ **អៀង ធីរិទ្ធ** ត្រូវស្ថិតក្រោមលក្ខខណ្ឌដូចខាងក្រោម:

១. ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាស័យដ្ឋាន ដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ។

២. ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

៣. ជនជាប់ចោទត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ។

**បង្គាប់ថា** ជនជាប់ចោទមានកាតព្វកិច្ចស្របតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ដោយមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**